# ការចិញ្ចឹមមាន់ តាមបច្ចេកទេសបែបវិទ្យាសាស្ត្រធម្មជាតិ

ការចិញ្ចឹមមាន់នៅក្នុងប្រទេសកម្ពុជាយើងនេះ កសិករភាគច្រើនចិញ្ចឹមមាន់ក្នុងស្រុក ចំពោះមាន់បរទេសមានការលូតលាស់លឿនមិនសូវមានអ្នកចិញ្ចឹម ដោយសារតែគ្មានកន្លែងផលិតពូជនៅក្នុងប្រទេស និងមានតំលៃខ្ពស់ព្រោះនាំចូលពីបរទេស ។ ខ្ញុំសូមណែនាំពីបទពិសោធន៍ចិញ្ចឹមតាមបច្ចេកទេសរបៀបវិទ្យាសាស្ត្រ ធម្មជាតិ អ៊ី អ៊ិក្ស អិម ។

## ១- ការចិញ្ចឹមមាន់មេ

ការរើសពូជ ត្រូវតាមដានរើសមេណាដែលជាពូជមាន់សាយកូន ឆ្អឹង និងដងខ្លួនសមរម្យល្មម មិនរើសពណ៌សម្បុរទ្រូងបើកទូលាយ ដងខ្លួនខ្លីល្មម គុម្ពកន្ទុយធំ ឆ្អឹងគូថនៅឃ្លាតឆ្ងាយពីគ្នា ។ គួរតែចាប់ចិញ្ចឹមពីមេមាន់ប្រាំក្បាល និងឈ្មោល ១ក្បាលឡើង តែត្រូវអនុវត្តអោយខ្ជាប់ខ្ជួន អ៊ី អ៊ិក្ស អិម ។

## ២- ការរៀបចំទ្រុង

សង់ទ្រុងបណ្ដោយថ្ងៃអោយបានល្អសំរាប់អោយមាន់ រោងធ្វើពីឈើ ឬ ឬស្សីប្រក់ស្លឹក ខាងក្រោមក្រាលស៊ីម៉ងត៍ (បើមានលទ្ធភាព) រោយអង្កាម ស្នូកទឹក និងស្នូកចំណីឧបករណ៍សំរាប់ធ្វើសំបុកអោយមាន់ពង ។

## ៣- ការបង្កាត់

ត្រូវមានមាន់ឈ្មោលធ្វើបា ១ក្បាល សំរាប់មាន់ញី ១ក្បាល រៀបចំកន្លែងសំរាប់បង្កាត់ផ្សេង សំរាប់ពងផ្សេង ។

## ៤- ការថែរក្សាមាន់ពង

ឧស្សាហ៍ជូត និងបង្វិលពងកុំឲ្យវាខះ បណ្ដោយអោយពងមិនញាស់ និងពិនិត្យមើលចំនួនពងអោយមេក្រាបចំនួន ១០ ទៅ ១២ពង សំរាប់មេ១ក្បាល ត្រូវយកស្លឹកស្ដៅ ឬថ្នាំជក់ទ្រាប់បាតសំបុកកុំឲ្យកើតស្រមើល ។

## ៥- ការមើលថែមាន់ញាស់ពង

ជាធម្មតាមាន់ក្រាបពងចំនួន ២០ ទៅ ២៣ថ្ងៃទើបញាស់កូន ។ ក្រោយកូនញាស់ ត្រូវយកទាំងមេទាំងកូនដាក់នៅក្នុងទ្រុងមួយដែលធ្វើពីក្រដាសរឹង ឬបន្ទះឬស្សីប្រវែងទទឹង ៨តឹក កំពស់ ៦តឹក ហើយត្រូវបិទបាំងអោយជិតនៅពេលយប់ ឬពេលមេឃត្រជាក់ ឬដុតធ្យូងដាក់ក្អមកំដៅ ។ ក្រុងទុកក្នុងទ្រុងនេះ ១០ទៅ ១៤ថ្ងៃ ដោយដាក់ទឹក និងចំណីអោយស៊ីផឹករាល់ថ្ងៃ ។ លុះដល់ថ្ងៃទី ១៥ទើបយកមេមកដាក់កន្លែងបង្កាត់វិញ រីឯកូនត្រូវយកទៅកន្លែងចិញ្ចឹមយកសាច់ ។

## ៦- ការថែរក្សាមាន់

យកមេ EX-Mលាយអោយមាន់ផឹកជាប្រចាំ ក្រោយពេលលាយផ្សំអោយផឹកសល់ មិនត្រូវយកទឹកដែលផឹកសល់នោះ លើសពី ២៤ម៉ោងមកប្រើទៀតឡើយ មានន័យថាប្ដូរទឹករៀងរាល់ ២៤ម៉ោងម្ដង ។

## កំរិតលាយប្រើ

– មេ EX-M១លីត្រ លាយទឹក ១០០០០លីត្រ សំរាប់មាន់ផឹករៀងរាល់ពេល (ទឹកស្អាត ១០លីត្រ លាយមេអ៊ីអ៊ិក្ស អិម ១សេសេ) ។

- យក EX-Mបណ្តេញ ២០សេសេ បូកមេ EX-M២០សេសេ ទឹក ១០លីត្រ បាញ់លើទ្រុងមាន់ទាំងក្នុង និងក្រៅ លើខ្លួនមាន់ សំបុក ស្នូកទឹក ស្នូកចំណី រៀងរាល់ ៥ទៅ ៧ថ្ងៃម្តង ។

- អោយចំណីមាន់ដែលធ្វើតាមបច្ចេកទេស EX-Mស៊ីគ្រប់គ្រាន់រាល់ពេល ។

– យកម្សៅសិរិទ្ធិ ១កញ្ចប់តូច លាយជាមួយចំណីមាន់ ៥គីឡូក្រាម ក្នុងមួយសប្តាហ៍ អោយមាន់ស៊ី ១ ឬ២ដង ។

- យកម្សៅសិរិទ្ធិ ១កញ្ចប់តូច លាយជាមួយទឹកស្អាត ៥លីត្រ អោយមាន់ផឹកមួយសប្តាហ៍ ២ដង ។

## ៧- ការចិញ្ចឹមមាន់សាច់

### ក- ការរៀបចំកន្លែងចិញ្ចឹម

- ក្រាលអង្កាមលើដី ឬលើកន្លែងក្រាលស៊ីម៉ង់ត៍កំពស់ ៨-១០សង់ទីម៉ែត្រ ទទឹង ១ម៉ែត្រ បណ្តោយ ៣ម៉ែត្រ ដាក់បានមាន់ចំនួន ២០-២៥ក្បាល ។

– យករនាបឬស្សីកំពស់ ៦តឹក ដែជាក្រឡាចក្រត្រង់បាំងជុំវិញបរិវេណចិញ្ចឹម ហើយយកសំណាញ់ ឬមុងចងបន្តពីរនាំងឫស្សីឡើងចំនួន ១ម៉ែត្រ ទៅ ១ម៉ែត្រកន្លះទៀត ។

- យកក្រណាត់ ឬបាវចាស់ៗ បាំងចងជាមួយរនាំងឫស្សីឡើងអោយបានកំពស់ ៣តឹក ។

### ខ- ការថែរក្សាព្យាបាលមាន់

– ការថែរក្សា : លាយមេ EX-Mអោយផឹករៀងរាល់ ២៤ម៉ោងម្តង ។

– បាញ់លើកន្លែងមាន់ និងបរិវេណជុំវិញពី ៥-៧ថ្ងៃម្តង ដោយប្រើ EX-Mបណ្តេញសត្វល្អិត ។

– យកមេ EX-M១សេសេ បូកកាកស្ករ ១សេសេ បូកទឹក ៥០០សេសេ លាយច្របល់ជាមួយចំណីមាន់ ៣ គីឡូក្រាម ។

– ការព្យាបាល : ករណីមាន់ឈឺ (មាន់សំកុក) ហៀរសំបោរ រាគស ឬរាគលឿងក្រម៉ៅ យកមេ EX-Mបណ្តេញ បូកមេ EX-Mបញ្ចុក ១ថ្ងៃ ២ដង ប្រើ ៣ថ្ងៃជាប់គ្នា ។

### កំរិតប្រើ

- ចំពោះមាន់តូច : EX-Mបណ្តេញ ១សេសេ បូកមេ EX-M១សេសេ ។

– ចំពោះមាន់ធំ : EX-Mបណ្តេញ ២សេសេ បូកមេ EX-M២សេសេ ។ ករណីមាន់មានស្នាមរបួសដោយជល់គ្នា យកមេ EX-Mលាប១ថ្ងៃ ៣ដង ដើម្បីអោយផ្សះដំបៅ និងការពារកុំអោយមេរោគឆ្លងចូល ឯមាន់ជល់វិញយកមេ EX-M លាយទឹកអោយងូតជារៀងរាល់ថ្ងៃ ។

- កំរិតលាយងូត : មេ EX-M១សេសេបូកទឹក ១លីត្រ ។

ខាងក្រោមនេះជាការផ្សំចំណីអាហារសំរាប់មាន់

| ចំពោះចំណីមាន់សាច់ | | ចំពោះចំណីមាន់ពង | | ចំពោះចំណីមាន់ក្នុងស្រុក | |
|---|---|---|---|---|---|
| ពោត | ៤០ គ.ក | ពោត | ៣៥ គ.ក | ស្រូវដំ | ៥ គ.ក |
| កន្ទក់ | ២៥ គ.ក | កន្ទក់ | ២៨គ.ក | កន្ទក់ | ១ គ.ក |
| សណ្ដែកសៀង | ២០ គ.ក | សណ្ដែកសៀង | ១៥ គ.ក | ត្រីម៉ត់ | ២ គ.ក |
| ត្រីម៉ត់ | ១៥ គ.ក | ត្រីម៉ត់ | ១៥ គ.ក | មេអាហារសត្វ | ១ ក្រាម |
| មេអាហារសត្វ | ២ គ.ក | សំបកងាវ | ៦ គ.ក | អំបិល | ១ស្លាបព្រាបាយ |
| អំបិល | ៤ ក្រាម | អំបិល | ៣ ក្រាម | ព្រីម៉ិច | ១ស្លាបព្រាបាយ |
| ព្រីម៉ិច | ៤ ក្រាម | មេអាហារសត្វ | ២ គ.ក | | |
| | | ព្រីម៉ិច | ៣ ក្រាម | | |

-----------------------------------------------------------------------------------------------------------------------

ដកស្រង់ចេញពី៖

http://sopheapprom.wordpress.com/2011/10/08/%E1%9E%80%E1%9E%B6%E1%9E%9A%E2%80%8B%E1%9E%85%E1%9E%B7%E1%9E%89%E1%9F%92%E1%9E%85%E1%9E%B9%E1%9E%98%E2%80%8B%E1%9E%98%E1%9E%B6%E1%9E%93%E1%9F%8B%E2%80%8B-%E1%9E%8F%E1%9E%B6%E1%9E%98%E2%80%8B%E1%9E%94/